គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ១០៣៨ លស /គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែ ធ្នូ ឆ្នាំ២០១៦

**គោរពជូន**

**ឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ៖** ស្តីពីការបំពេញទិន្នន័យ និងព័ត៌មានពាក់ព័ន្ធនឹងកិច្ចដំណើរការនៃការិយាល័យជំនាញនានានៅថ្នាក់ក្រុង ស្រុក ខណ្ឌ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម** ជ្រាបថា រាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប) ដឹកនាំសម្របសម្រួលក្នុងការសិក្សាអំពីស្ថានភាព និងកិច្ចដំណើរការនៃការិយាល័យជំនាញនានានៅថ្នាក់ក្រុង ស្រុក ខណ្ឌ ដើម្បីពិនិត្យមើលឡើងវិញនូវការរៀបចំរចនាសម្ព័ន្ធ និងការកំណត់បែងចែកតួនាទី ភារកិច្ចឱ្យបានច្បាស់លាស់នៅថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងគោលបំណងពង្រឹង និងកែលម្អគុណភាពនិងប្រសិទ្ធភាពនៃការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន។ គ.ជ.អ.ប បានបង្កើតក្រុមការងារអន្តរក្រសួងដែលមានសមាសភាពមកពីតំណាងនៃកម្មវិធីកំណែទម្រង់ទាំងបី គឺកម្មវិធីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ។ ក្រុមការងារបានរៀបចំនូវបញ្ជីទិន្នន័យសំខាន់ៗមួយចំនួនដែលត្រូវប្រមូលពីក្រុង ស្រុក ខណ្ឌទាំងអស់ទូទាំងប្រទេស ដើម្បីធ្វើការវិភាគ និងលើកអនុសាសន៍ជូនគ.ជ.អ.ប. ដើម្បីពិនិត្យ និងសុំយោបល់សម្រេចពីប្រមុខរាជរដ្ឋាភិបាល អំពីការកែសម្រួលរចនាសម្ព័ន្ធ និងការកំណត់បែងចែកតួនាទី ភារកិច្ចរបស់ការិយាល័យជំនាញនៅថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ឱ្យបានច្បាស់លាស់។ ដើម្បីជួយសម្រួលដល់ក្រុមការងារសិក្សានេះ ខ្ញុំស្នើសុំឯកឧត្តមអភិបាលរាជធានី ខេត្តមេត្តាជួយសម្របសម្រួលការងារដូចខាងក្រោម៖

១. ស្នើបញ្ជូនបញ្ជីទិន្នន័យស្តីពីស្ថានភាពរបស់ការិយាល័យជំនាញទាំងអស់នៅថ្នាក់ក្រុង ស្រុក ខណ្ឌ សម្រាប់ឆ្នាំ២០១៦ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌទាំងអស់ ដើម្បីសម្របសម្រួលជាមួយការិយាល័យជំនាញក្នុងការបំពេញនូវទិន្នន័យ និងព័ត៌មានសំខាន់ៗមួយចំនួន(សូមភ្ជាប់ជូនមកជាមួយនូវបញ្ជីទិន្នន័យរួមអំពីស្ថានភាពនៃការិយាល័យជំនាញនៅថ្នាក់ក្រុង ស្រុក ខណ្ឌ)

២. ស្នើចាត់តាំងនាយករងរដ្ឋបាលសាលារាជធានី ខេត្ត០១រូប និងទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់រាជធានី ខេត្តជាជនបង្គោលក្នុងការសម្របសម្រួល និងជួយគាំទ្រដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ លើការបំពេញបញ្ជីទិន្នន័យអំពីស្ថានភាពនៃការិយាល័យជំនាញនានានៅថ្នាក់ក្រុង ស្រុក ខណ្ឌ

ព្រមទាំងធ្វើការប្រមូល និងបញ្ជូនបញ្ជីទិន្នន័យដែលបំពេញរួមមកលេខាធិការដ្ឋានគ.ជ.អ.ប. ត្រឹម **ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ តាមរយៈអ៊ីម៉ែល** bunnakg@gmail.com **ឬ** bunnakong@ncdd.gov.kh។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម**ឯកឧត្តម** មេត្តាជួយសម្របសម្រួល និងចាត់ចែងអនុវត្តតាមការគួរ។

សូម **ឯកឧត្តម** ទទួលនូវការគោរពរាប់អានដោយស្មោះអំពីខ្ញុំ។

**ជ. ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

***ទំនាក់ទំនង៖***

- លោក សុខ សុទ្ធី ០១២ ៩១១ ៦៤២
- កញ្ញាគង់ ប៊ុណ្ណា ០១២ ២២២ ៧៧៦
- ឈិន ទេពីរម្យ ០១២ ៨៣៥ ៩៩១